ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៦៤០ សហវ.ប្រក.៣៥

# ប្រកាស
## ស្តីពី
## ការបែងចែកប្រាក់រង្វាន់នៃការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០០៥

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញក្រឹត្យលេខ ២៤/ក្រ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៩១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០១៩៨/០១ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ១៩៩៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៨
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០២/០២១ ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរប់ការគ្រប់គ្រងឆ្នាំ ២០០៣
- បានឃើញអនុក្រឹត្យលេខ ០៨/អនក្រ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩១ ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ
- បានឃើញប្រកាសលេខ ០០៤ ប្រក/សបវ/ពជ ចុះថ្ងៃទី ០៤ ខែមករា ឆ្នាំ២០០១ ស្តីពីការផ្តល់រង្វាន់ជូនអង្គភាពពន្ធដារ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣ ៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញប្រកាសលេខ ២៨៧ សហវ/ពដ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០០៣ ស្តីពីការបែងចែកប្រាក់រង្វាន់របស់អង្គភាពពន្ធដារ
- បានឃើញប្រកាសលេខ ២៧០ សហវ/ប្រក ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ២០០៥ ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ សំរាប់ឆ្នាំ២០០៥
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០០៥

## សំរេច

**ប្រការ ១ :** ចាប់ពីថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ២០០៥តទៅ អង្គភាពពន្ធដារនឹងធ្វើការត្រួតពិនិត្យជាកពិន័យចំនួនមួយដងស្មើប្រាក់ពន្ធបន្ថែមលើប្រាក់ពន្ធដែលត្រូវបង់ចំពោះមធ្យោបាយដឹកជញ្ជូន និង យានជំនិះទាំងឡាយណាដែលមិនបានបង់ពន្ធសំរាប់ឆ្នាំ២០០៥ ដូចបានកំណត់ក្នុងប្រការ ១ នៃប្រកាសលេខ ២៧០ សហវ.ប្រក ចុះថ្ងៃទី០៣ ខែ មិថុនា ឆ្នាំ២០០៥ ។

ប្រាក់ពិន័យដែលទទួលបានមកអំពីការពិន័យលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០០៥ត្រូវបានអនុញ្ញាតឱ្យបែងចែកដូចតទៅ :

ក-ប្រាក់ពិន័យដែលទទួលបានក្នុងកិច្ចប្រតិបត្តិការត្រួតពិនិត្យ *(នៅទីចំណតនានា)* ដែលមានសហការរវាងមន្ត្រីពន្ធដារ និង មន្ត្រីមានសមត្ថកិច្ចដែលបានចូលរួម ត្រូវបានអនុញ្ញាតឱ្យបែងចែកដូចតទៅ :

១- ៥០% (ហាសិបភាគរយ) ត្រូវបង់ចូលថវិការដ្ឋ ។

២- ៥០% (ហាសិបភាគរយ) ត្រូវបានអនុញ្ញាតឱ្យបែងចែកជាប្រាក់រង្វាន់ដូចតទៅ :

- ១៥% (ដប់ប្រាំភាគរយ) បង់ចូលនាយកដ្ឋានពន្ធដារ
- ៣៥%(សាមសិបប្រាំភាគរយ)សំរាប់បែងចែកដូចខាងក្រោម :
  + ៦០% នៃប្រាក់រង្វាន់ សំរាប់ចែកជូនសមាជិកនៃក្រុមប្រតិបត្តិការត្រួតពិនិត្យ ។
  + ២០% នៃប្រាក់រង្វាន់ សំរាប់បេឡាសមូហភាពរបស់សាខាពន្ធដារខេត្ត-ក្រុង ។
  + ១០% នៃប្រាក់រង្វាន់ សំរាប់បេឡាសមូហភាពរបស់សាលាខេត្ត-ក្រុង ។
  + ១០% នៃប្រាក់រង្វាន់ សំរាប់បេឡាសមូហភាពរបស់សាលាខ័ណ្ឌ-ស្រុក ។

ខ-ប្រាក់ពិន័យដែលទទួលបានក្នុងកិច្ចប្រតិបត្តិការត្រួតពិនិត្យ*(នៅក្នុង ភូមិ ឃុំ-សង្កាត់)*ដែលមានសហការរវាងមន្ត្រីពន្ធដារ នគរបាលឃុំ-សង្កាត់ ក្រុមប្រឹក្សាឃុំ-សង្កាត់ និងមន្ត្រីមានសមត្ថកិច្ចផ្សេងទៀតដែលបានចូលរួមត្រូវបានអនុញ្ញាតឱ្យបែងចែកដូចតទៅ :

១- ៥០% (ហាសិបភាគរយ) ត្រូវបង់ចូលថវិកាជាតិ ។

២- ៥០% (ហាសិបភាគរយ) ត្រូវបានអនុញ្ញាតឱ្យបែងចែកជាប្រាក់រង្វាន់ដូចតទៅ :

- ១៥% (ដប់ប្រាំភាគរយ) បង់ចូលនាយកដ្ឋានពន្ធដារ

- ៣៥%(សាមសិបប្រាំភាគរយ)សំរាប់បែងចែកដូចខាងក្រោម :

+ ៥០% នៃប្រាក់រង្វាន់ សំរាប់ចែកជូនសមាជិកនៃក្រុមប្រតិបត្តិការត្រួតពិនិត្យ ។

+ ២០% នៃប្រាក់រង្វាន់ សំរាប់បេឡាសមូហភាពរបស់សាខាពន្ធដារខេត្ត-ក្រុង ។

+ ១០% នៃប្រាក់រង្វាន់ សំរាប់បេឡាសមូហភាពរបស់សាលាខេត្ត-ក្រុង ។

+ ១០% នៃប្រាក់រង្វាន់ សំរាប់បេឡាសមូហភាពរបស់សាលាខ័ណ្ឌ-ស្រុក ។

+ ១០% នៃប្រាក់រង្វាន់ សំរាប់បេឡាសមូហភាពរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ ។

**ប្រការ ២ :** អនុញ្ញាតឱ្យសាខាពន្ធដារខេត្ត-ក្រុងនីមួយៗ ដកប្រាក់រង្វាន់ពីការផាកពិន័យពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០០៥នេះភ្លាមសំរាប់បែងចែកជូនសមាជិកក្រុមត្រួតពិនិត្យនិងអង្គភាព តាមសមាមាត្រដូចបានចែងក្នុងប្រការ១ខាងលើ ហើយត្រូវធ្វើរបាយការណ៍បូកសរុបពីស្ថានភាពចំណូល និង ចំណាយបេឡាប្រាក់រង្វាន់ជូននាយកដ្ឋានពន្ធដារ ដើម្បីពិនិត្យ និង សំរេចទូទាត់ជាក្រោយ ។

**ប្រការ ៣ :** ប្រកាសនេះ មានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ តុលា ឆ្នាំ២០០៥

**គាត ឈន់**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជារបាយការណ៍"
- គ្រប់ក្រសួង-ស្ថាប័នកណ្តាល
- គ្រប់សាលាខេត្ត-ក្រុង

"ដើម្បីជូនជ្រាបជាពត៌មាន"

- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

"ដើម្បីមុខការ"

- គ្រប់សាខាពន្ធដារខេត្ត-ក្រុង "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ